ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៣ សជណ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
## ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១

- *សូមថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !*
- *សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី !*
- *បងប្អូន កូនក្មួយ ចៅៗ ជនរួមជាតិទាំងអស់ជាទីស្រលាញ់ !*

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមជាភាគីហត្ថលេខីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងគ្រឿងញៀន ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមសម្តែងនូវមនោសញ្ចេតនារីករាយ ចូលរួម និងគាំទ្រយ៉ាងពេញទំហឹងចំពោះខ្លឹមសារ និងការរៀបចំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ក្រោមប្រធានបទ ***"ចែករំលែកព័ត៌មានពិតពីគ្រោះថ្នាក់នៃគ្រឿងញៀន គឺជួយសង្គ្រោះជីវិត - Share Facts on Drugs, Save Lives"*** ក្នុងគោលបំណងបន្តបំផុសឱ្យជនគ្រប់រូបបង្កើនការស្វែងយល់អំពីគ្រោះថ្នាក់នៃគ្រឿងញៀន ក៏ដូចជាយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់ចំណេះដឹង និងមានភស្តុតាងធ្វើជាមូលដ្ឋាន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការចូលរួមបង្ការ ទប់ស្កាត់ ព្យាបាល ដល់ជនដែលងាយនិងកំពុងរងគ្រោះដោយសារគ្រឿងញៀននិងចែករំលែកព័ត៌មានពិតក្នុងការដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ទាំងក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។ ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងនូវសារលិខិតប្រគេនសម្តេចព្រះមហាសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូន កូនក្មួយ ចៅៗ ជនរួមជាតិទាំងអស់ពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមកម្មវិធីនយោបាយ ផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងស្ថានភាពជាក់ស្តែងនៃបញ្ហាគ្រឿងញៀន ក៏ដូចជាបញ្ហាសង្គមផ្សេងៗទៀត ជាពិសេស នៅក្នុងស្ថានភាពដ៏លំបាកបំផុតរបស់ប្រវត្តិសាស្ត្រទំនើបពិភពលោក ដែលទទួលរងដោយរោគរាតត្បាតជំងឺកូវីដ-១៩ ដែលបាន និងកំពុងបន្តជះឥទ្ធិពលជាវិបត្តិសុខភាពសាធារណៈ និងការបន្ទុចបង្អាក់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចសកល និងបានបង្កឱ្យប្រជាជនលើពិភពលោករាប់លាននាក់បានបាត់បង់ជីវិត។

សម្រាប់ឆ្នាំ២០២១នេះ បើទោះបីជាសកលលោក ក៏ដូចជាប្រទេសជាតិយើងនៅតែបន្តទទួលរង ឥទ្ធិពលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែសម្រេចបន្តរៀបចំប្រារព្ធទិវាអន្តរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងកម្រិតថ្នាក់ជាតិ ក្រោមប្រធានបទ " ***គ្មានគ្រឿងញៀន និងគ្មានជំងឺកូវីដ-១៩ សហគមន៍មានសុវត្ថិភាព និងការអភិវឌ្ឍន៍*** " ក្នុងរូបភាពជាយុទ្ធនាការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន តាមបណ្តាញទំនាក់ទំនងសង្គម និងការរៀបចំដុតបំផ្លាញគ្រឿងញៀនដែលចាប់យកបានក្នុងប្រតិបត្តិការ បង្ក្រាបបទល្មើសគ្រឿងញៀននាពេលកន្លងមក។ ការបន្តរៀបចំប្រារព្ធទិវាអន្តរជាតិ និងលើកយកប្រធានបទ ថ្នាក់ជាតិបន្ថែមនេះ គឺដើម្បីបន្តពញ្ញាក់ស្មារតីជនរួមជាតិទាំងអស់ ឱ្យយកចិត្តដាក់កាន់តែខ្លាំងថែមទៀត ក្នុងការបន្តចូលរួមបង្ការ ទប់ស្កាត់ ព្យាបាល និងដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ហើយជាមួយគ្នានោះ ក៏ត្រូវយកចិត្តទុកដាក់ឱ្យបានជាប់ជាប្រចាំក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មកលើខ្លួនឯង មកលើក្រុមគ្រួសារ កន្លែងធ្វើការ និងសហគមន៍ដែលខ្លួនរស់នៅ ជាពិសេស ធ្វើឱ្យជនគ្រប់រូបចងចាំថា ការដោះស្រាយបាននូវបញ្ហាគ្រឿងញៀន និងការបង្ការកុំឱ្យមានការឆ្លងថ្មីនៃជំងឺ កូវីដ-១៩ គឺជាកត្តាដ៏សំខាន់ក្នុងការថែរក្សាសុខភាព សុវត្ថិភាព សន្តិសុខ និងបង្កើនការអភិវឌ្ឍសម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

ក្នុងពេលកន្លងមកនេះ ស្ថានភាពនៃការដាំដុះ ការផលិត ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ទាំងនៅក្នុងតំបន់ និងសកលលោក រួមនិងការប្រើប្រាស់សារធាតុញៀនថ្មីប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ នៅមិនមានសញ្ញាថយចុះនៅឡើយទេ ហើយបាននិងកំពុងរីករាលដាលគួរឱ្យព្រួយបារម្ភ។ ជាមួយគ្នានេះ ឥទ្ធិពលនៃការប្រណាំងប្រជែងនយោបាយ-សេដ្ឋកិច្ច របស់ប្រទេសមហាអំណាចនៅក្នុងនិងក្រៅតំបន់ ពិសេសវិបត្តិដែលពាក់ព័ន្ធនឹងការឆ្លងរាលដាលជំងឺកូវីដ-១៩ បានគំរាមកំហែង និងបង្កនូវផលលំបាក យ៉ាងធ្ងន់ធ្ងរដល់ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចជាសកល។ កត្តាទាំងអស់នេះបាននាំមកនូវផលប៉ះពាល់ អវិជ្ជមានដល់សុខភាពសាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព របស់ប្រទេសនានានៅក្នុងពិភពលោក ដែលក្នុងនោះមានប្រទេសកម្ពុជាយើងផងដែរ។ ប៉ុន្តែទោះបីជា យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តយកចិត្តទុកដាក់ ខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ និង ប្រើប្រាស់គ្រប់លទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹង គ្រឿងញៀន ទាំងក្នុងកម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ជាក់ស្តែង យើងបានបន្តរឹតបន្តឹង និងលើកកម្ពស់ ការទទួលខុសត្រូវ ក្នុងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវរាល់គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដែលមានការពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិសេសផែនការយុទ្ធនាការ ប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ និងលើកទី៦ ដែលរាជរដ្ឋាភិបាលបានដាក់ចេញរហូតទទួល បានលទ្ធផលគួរជាទីមោទនៈ។ ជាការពិតវិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ មិនអាចឱ្យយើងធ្វើសកម្មភាព អប់រំផ្សព្វផ្សាយដោយផ្ទាល់នៅតាមសហគមន៍បានច្រើនឡើយ ប៉ុន្តែយើងមិនបានបន្ធូរ ឬបោះបង់សកម្មភាព ដ៏មានសារៈសំខាន់នេះឡើយ។ ផ្ទុយទៅវិញ ក្រសួង ស្ថាប័ន អង្គភាព និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក៏ដូចជាវិស័យសាសនា វិស័យឯកជន អង្គការ សមាគមជាតិ អន្តរជាតិជាដៃគូ និងបងប្អូន ជនរួមជាតិមួយចំនួនធំនៅតែបន្តខិតខំប្រឹងប្រែង ដោយបានប្រើប្រាស់វិធីសាស្ត្រថ្មីៗ ធ្វើការអប់រំផ្សព្វផ្សាយ និងចែករំលែកព័ត៌មានដែលជាប្រយោជន៍ ដល់ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់ នៃគ្រឿងញៀន ក៏ដូចជាលើកកម្ពស់ប្រសិទ្ធភាពនៃការបង្ការ ទប់ស្កាត់ ព្យាបាល និងដោះស្រាយរាល់បញ្ហា

ដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ដោយរួមទាំងបញ្ហាសង្គមផ្សេងៗ និងបញ្ហានៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ផងដែរ។ ជាមួយនោះដែរ អង្គភាពអនុវត្តច្បាប់គ្រប់ប្រភេទ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ក៏បានបន្តនិងបង្កើនសកម្មភាពរដ្ឋបាល និងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់ការប៉ុនប៉ង កែច្នៃ ផលិត រក្សាទុក ជួញដូរ និងចរាចរគ្រឿងញៀនខុសច្បាប់ទាំងមកពីខាងក្រៅ និងនៅផ្ទៃក្នុងប្រទេស។ ជាក់ស្តែងបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀនចំនួន១០ ៤៦១ករណីត្រូវបានបង្ក្រាបក្នុងឆ្នាំ២០២០ គឺបង្ក្រាបបានច្រើនជាងឆ្នាំមុនប្រមាណ ៦,៧៩% ជនសង្ស័យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនចំនួន២១ ៥៦៦នាក់ ត្រូវបានឃាត់ខ្លួន គឺច្រើនជាងឆ្នាំមុនប្រមាណ៥,២៥% និងចាប់យកគ្រឿងញៀនគ្រប់ប្រភេទបាន ៣ ៨៧៥គក្រ ៨៧៨ក្រ ដែលបរិមាណនេះមានការកើនឡើងប្រមាណ៥១៦% បើប្រៀបធៀបទៅនឹងបរិមាណដែលចាប់យកបានក្នុងឆ្នាំមុន។ ជាមួយគ្នានោះ យើងក៏នៅបានបន្តយ៉ាងសកម្មក្នុងការជួយសង្គ្រោះជនរងគ្រោះដោយសារគ្រឿងញៀន ដោយផ្តល់ការព្យាបាលនិងស្តារនីតិសម្បទាដល់ពួកគាត់ទាំងនៅតាមសហគមន៍ និងនៅតាមមណ្ឌលបណ្តោះអាសន្នបានចំនួន ១៩ ៥៩៧ នាក់ រហូតធ្វើឱ្យពួកគេមួយចំនួនធំទទួលបានមកវិញនូវសុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត ចំណេះ និងជំនាញមួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានក្នុងការប្រកបរបរចិញ្ចឹមជីវិត និងកសាងគ្រួសារមួយដ៏សមរម្យនៅក្នុងសង្គមជាតិ។ លទ្ធផលដែលសម្រេចបានគួរជាទីមោទនៈទាំងនេះ គឺពិតជាមិនអាចកាត់ផ្តាច់បានពីការចូលរួមចំណែកយ៉ាងសកម្មរបស់បងប្អូនជនរួមជាតិទាំងអស់ ដែលឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអរព្រះគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះសម្តេចព្រះមហាសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមអរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ព្រមទាំងវិស័យឯកជន សប្បុរសជន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិជាដៃគូ ក៏ដូចជាបងប្អូន ជនរួមជាតិទាំងអស់ដែលបានផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹង និងចូលរួមយ៉ាងសកម្មផុលផុសទាំងក្នុងពេលកន្លងមក ក៏ដូចជានាពេលបច្ចុប្បន្ននេះ។

ទោះបីជាយើងសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈក៏ដោយ ក៏បញ្ហាគ្រឿងញៀននៅតែជាបញ្ហាសង្គមដ៏ស្មុគស្មាញមួយ ដែលបានគំរាមកំហែងដល់សុខភាពសាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍសង្គមរបស់យើង។ ដូច្នេះដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលបន្ថែមទៀតលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងដំណាក់កាលនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ឱ្យស្របតាមខ្លឹមសារនៃប្រធានបទដែលបានលើកឡើងសម្រាប់ឆ្នាំនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមធ្វើការណែនាំ និងអំពាវនាវដូចតទៅ៖

១- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ព្រមទាំងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ត្រូវបន្តយកចិត្តទុកដាក់ម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់អនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន នូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៦ ដែលរាជរដ្ឋាភិបាលបានដាក់ចេញនាពេលកន្លងទៅនេះ។ ជាមួយនេះ ត្រូវធ្វើការដាស់តឿន ក្រើនរំលឹក និងណែនាំមន្ត្រីប្រតិបត្តិរបស់ខ្លួនឱ្យបានជាប្រចាំក្នុងការអនុវត្តការផ្លាស់ប្តូរ កែប្រែទម្លាប់ និងឥរិយាបថនៃការបំពេញភារកិច្ចឱ្យស្របទៅតាមរបត់នៃការរស់នៅ

"សកម្មភាពធម្មតាតាមបែបគន្លងថ្មី (New Normal Life) ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩" ដោយប្រកាន់យកនូវវិធានការ "*៣ការពារ ៣កុំ* " និងវិធានការសុខាភិបាលផ្សេងៗទៀត ដើម្បីចូលរួមបង្ការ ទប់ស្កាត់ និងឈានទៅដល់ការកាត់ផ្តាច់ខ្សែចម្លងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមកន្លែងធ្វើការមកលើខ្លួនឯង ក្រុមគ្រួសារ និងសហគមន៍។

២- គណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយអប់រំ ត្រូវបន្តជំរុញដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តទាំងអស់ រោងចក្រ សហគ្រាស ធ្វើការអប់រំផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀនឱ្យស្រុះស្រួលគ្នា ជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គម ក្នុងបរិបទជំងឺកូវីដ-១៩។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តដឹកនាំ និងណែនាំដល់គ្រឹះស្ថានអប់រំសិក្សាគ្រប់កម្រិតឱ្យរកគ្រប់វិធីសាស្ត្រ ក្នុងការបន្តផ្សព្វផ្សាយអប់រំ ទាំងលើបញ្ហាគ្រឿងញៀន និងបញ្ហានៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ឱ្យបានជាប្រចាំដល់សិស្ស និស្សិត ដើម្បីឱ្យពួកគេបានយល់ដឹង និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការការពារខ្លួន និងបន្តផ្សព្វផ្សាយអប់រំដល់មិត្តភក្តិ ក្រុមគ្រួសារ និងអ្នកដទៃនៅក្នុងសហគមន៍។

៣- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តទាំងអស់ ត្រូវម្ចាស់ការ និងទទួលខុសត្រូវក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយនូវរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ដោយប្រកាន់ឱ្យបានខ្ជាប់ខ្ជួន និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវទិសស្លោកប្រយុទ្ធប្រឆាំងគ្រឿងញៀន "*៣កុំ ១រាយការណ៍*" ដែលក្នុងនោះរួមមាន៖ ទី១) *កុំពាក់ព័ន្ធ* មានន័យថា កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិត និងកុំប្រើប្រាស់គ្រឿងញៀន។ ទី២) *កុំអន្តរាគមន៍* មានន័យថា កុំរាំងការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារ សាច់ញាតិ ឬមិត្តភក្តិក៏ដោយ និងទី៣) គឺ *កុំលើកលែង* ដែលមានន័យថា កុំបន្ធូរបន្ថយការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តច្បាប់ដោយម៉ឺងម៉ាត់និងស្មោះត្រង់វិជ្ជាជីវៈរបស់ខ្លួន ហើយជនគ្រប់រូបត្រូវគោរព និងអនុវត្តច្បាប់។ ឯ *១រាយការណ៍* គឺត្រូវរាយការណ៍ ផ្តល់ព័ត៌មានដល់សមត្ថកិច្ចពីបញ្ហាគ្រឿងញៀនដែលយើងបានដឹង។ ជាមួយនេះ ត្រូវបន្តបំផុសឱ្យមាតាបិតា អាណាព្យាបាល យកចិត្តទុកដាក់ និងចូលរួមឱ្យកាន់តែសកម្មថែមទៀតក្នុងការអប់រំកូនចៅកុំឱ្យមានការពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ឬអប់រំ ណែនាំ និងលើកទឹកចិត្តកូនចៅដែលពាក់ព័ន្ធ ឬញៀនគ្រឿងញៀនឱ្យបញ្ឈប់ និងទៅទទួលយកការព្យាបាល និងស្តារនីតិសម្បទាឱ្យបានទាន់ពេលវេលា។

៤- គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវបន្តពង្រឹងសមត្ថភាព និងគុណភាពនៃការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងនៅតាមមូលដ្ឋានសុខាភិបាល និងនៅតាមមណ្ឌលបណ្តោះអាសន្ន ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន។ ជាមួយនេះ ក្នុងកាលៈទេសៈនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ត្រូវគិតគូរឱ្យបានហ្មត់ចត់ និងរកវិធានការឱ្យបានត្រឹមត្រូវ ដើម្បីធានាប្រសិទ្ធភាពនៃការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមគោលដៅផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

៥- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការបង្កើនសមត្ថភាពមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ដើម្បីសម្រួលដល់ការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាឱ្យបានសមស្រប និងមានប្រសិទ្ធភាព ពិសេសដើម្បីបញ្ចៀសភាពចង្អៀតណែនដែលអាចកើតមាននៅតាមមណ្ឌលបណ្តោះអាសន្ននានា។ ពង្រឹងវិធានការ **៣ការពារ ៣កុំ** និងវិធានការសុខាភិបាលផ្សេងៗទៀតនៅតាមមណ្ឌលបណ្តោះអាសន្នទាំងអស់ និងត្រូវសហការជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីទប់ស្កាត់នៃការរីករាលដាលជំងឺកូវីដ-១៩។

៦- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការពង្រឹង និងពង្រីកបន្ថែមឱ្យបានទូលំទូលាយនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី តំបន់ និងជាសកល ដើម្បីទប់ស្កាត់ ការចរាចរ ជួញដូរគ្រឿងញៀនខុសច្បាប់ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវចំពោះសម្តេចព្រះមហាសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃស្ថាប័នរាជរដ្ឋាភិបាល វិស័យឯកជន សប្បុរសជន អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិជាដៃគូ ក៏ដូចជាបងប្អូនកូនក្មួយជាជនរួមជាតិទាំងអស់ សូមបន្តចូលរួមគាំទ្រ និងឧបត្ថម្ភ ឱ្យបានកាន់តែសកម្មថែមទៀត ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់ និងដោះស្រាយនូវរាល់បញ្ហាគ្រឿងញៀនដែលអាចកើតមាននៅក្នុងសហគមន៍។ ជាមួយនេះ ខ្ញុំក៏សូមអំពាវនាវចំពោះមាតាបិតា និងអាណាព្យាបាល សូមបន្តយកចិត្តទុកដាក់ថែទាំ និងអប់រំកូនចៅឱ្យបានល្អ ដើម្បីកុំឱ្យមានការពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន កុំឱ្យឆ្លងជំងឺកូវីដ-១៩ និងចៀសឱ្យផុតពីបញ្ហាអវិជ្ជមានផ្សេងៗនៅក្នុងសង្គម។ ក្នុងករណីដឹងថា កូនចៅរបស់ខ្លួនជាប់ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវយកចិត្តទុកដាក់ផ្តល់កិច្ចសហការ ឬរាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន ឬសមត្ថកិច្ចជំនាញ ដើម្បីសុំកិច្ចអន្តរាគមន៍ ដោយមិនត្រូវព្យាយាមលាក់បាំង ឬរក្សាទុក ដែលអាចបង្កគ្រោះថ្នាក់ និងភាពឈឺចាប់កាន់តែធ្ងន់ធ្ងរដល់ខ្លួនគាត់ផ្ទាល់ ក្រុមគ្រួសារ អ្នកដទៃ និងសហគមន៍ទាំងមូលឡើយ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានជំនឿជាក់យ៉ាងមុតមាំថា សម្តេច ព្រះមហាសង្ឃរាជទាំងពីរគណៈព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូន កូនក្មួយ ជនរួមជាតិទាំងអស់ ពិសេសស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗទៀត នឹងចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបានជាឧត្តមប្រយោជន៍រួមដល់ប្រជាពលរដ្ឋ និងប្រទេសជាតិនៃយើង។

ជាទីបញ្ចប់ ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ ប្រគេនពរ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ និងសូមជូនពរជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**